# ខ្ញុំជាគ្រិស្តសាសនិក !

ដោយ ម៉ារីស្សា វីដឌីសុន
ទស្សនាវដ្ដីសាសនាចក្រ



ពេលខ្ញុំទទួលបុណ្យជ្រមុជទឹក
និងពិធីបញ្ជាក់ នោះខ្ញុំបានយក
ព្រះនាមនៃព្រះគ្រីស្ទ ។
នោះមានន័យថា ខ្ញុំជ្រើសរើស
ធ្វើតាមទ្រង់ ហើយព្យាយាម
ធ្វើនូវអ្វីដែលត្រឹមត្រូវ ។



ខ្ញុំជាគ្រិស្តសាសនិក ! ខ្ញុំជឿថា ព្រះគ្រីស្ទគឺជា
ព្រះរាជបុត្រាបង្កើតតែមួយរបស់ព្រះ—
ព្រះអម្ចាស់នៃមេត្រីភាព អ្នកគង្វាលល្អ
នំបុ័ងនៃជីវិត ព្រះដ៏បរិសុទ្ធ ។



ខ្ញុំជាគ្រិស្តសាសនិក ! ខ្ញុំអានព្រះគម្ពីររៀងរាល់ថ្ងៃ ដោយរៀនពីព្រះជន្មរបស់ទ្រង់
អព្ភូតហេតុ ការបង្រៀន ការពលិកម្មអស់កល្បរបស់ទ្រង់ ។



ខ្ញុំជាគ្រិស្តសាសនិក ! ខ្ញុំចង់ឲ្យពិភពលោកដឹងថា ព្រះយេស៊ូវបានសុគតសម្រាប់ពួកគេ ។
ដោយសារទ្រង់បានថ្វាយព្រះជន្មទ្រង់សម្រាប់ពួកយើង នោះ
យើងទាំងអស់គ្នានឹងរស់ឡើងវិញម្ដងទៀត !



ខ្ញុំជាគ្រិស្តសាសនិក ! ពេលព្រលឹងខ្ញុំមានអារម្មណ៍
ឈឺចាប់ដោយសារអំពើបាប ឬកង្វល់នៃលោកិយ
នោះខ្ញុំបានបង្វែរចិត្តខ្ញុំទៅកាន់ព្រះយេស៊ូវ
ហើយខ្ញុំដឹងថា ទ្រង់គង់នៅទីនោះ ។



ខ្ញុំជាគ្រិស្តសាសនិក ! ខ្ញុំប្រើអ្វីដែលខ្ញុំមាន
ដើម្បីជួយមិត្តភក្ដិខ្ញុំនៅពេលខ្វះខាត ។
ខ្ញុំបានព្យាយាមធ្វើអ្វីដែលព្រះគ្រីស្ទ
បានធ្វើ ខ្ញុំកំពុងដើរតាមទ្រង់ ។



ខ្ញុំជាគ្រិស្តសាសនិក ! ខ្ញុំអភ័យទោសដល់
អ្នកទាំងឡាយណាដែលជ្រើសរើសធ្វើខុស ។
ខ្ញុំស្វាគមន៍ភាពសុខសាន្ត មិត្តភាព
ហើយជួយមនុស្សឲ្យត្រូវគ្នា ។



ខ្ញុំជាគ្រិស្តសាសនិក !
ខ្ញុំចងចាំព្រះគ្រីស្ទតាមរបៀប
ដែលទ្រង់សុំឲ្យយើងធ្វើ ៖
ខ្ញុំទទួលទានសាក្រាម៉ង់
រៀងរាល់សប្ដាហ៍ ហើយ
សន្យាថាស្មោះត្រង់ ។



ខ្ញុំជាគ្រិស្តសាសនិក ! ទោះបីជានៅតែ
ឯងក្ដី ខ្ញុំបង្ហាញនូវភាពថ្លៃថ្នូរ ។
ខ្ញុំស្មោះត្រង់ ក្លាហាន ហើយមានគុណ
ធម៌ ។ អ្នកអាចពឹងផ្អែកលើខ្ញុំបាន ។



ខ្ញុំជាគ្រិស្តសាសនិក !
ខ្ញុំស្រឡាញ់ព្រះយេស៊ូវគ្រីស្ទដោយ
អស់ពីចិត្តខ្ញុំ ។ វាជាការពិត !
ឥឡូវនេះជាវេនរបស់អ្នកហើយ—
សូមអ្នកចែកចាយពីអត្ថន័យនៃ
ការធ្វើជាគ្រិស្តសាសនិក ! ●

**តើអ្នកដឹងទេ ?**
ឈ្មោះ « គ្រិស្តសាសនិក »
គឺជាឈ្មោះដំបូងគេដែលបាន
ប្រើនៅក្នុងព្រះគម្ពីរសញ្ញាថ្មី
ដើម្បីពិពណ៌នាអំពីប្រជាជន
នៅក្នុងទីក្រុងអាន់ទីយ៉ូកដែល
បានធ្វើតាមព្រះយេស៊ូវ ។
អ្នកអាចអានអំពីពួកគេនៅក្នុង
កិច្ចការ ១១:២៦ ។